វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

# បេសកកម្មកសាងភាពប្រសើរឡើងសម្រាប់កម្ពុជា

នៅក្នុងបន្ទប់ការិយាល័យនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា(NGOF) លោក តឹក វណ្ណារ៉ា កំពុងបំពេញការងារប្រចាំថ្ងៃរបស់លោក រួមមានការពិនិត្យមើល ឆ្លើយតប និងផ្ទៀងផ្ទាត់ឯកសារផ្សេងៗ ពីគម្រោងកម្មវិធីខុសៗគ្នា ដើម្បីធានាឲ្យបាននូវវឌ្ឍនភាពដ៏រលូននៅក្នុងស្ថាប័នការងារ។ យូរៗម្តង លោកទទួលទូរសព្ទ័ពីសហការី និងភាគីពាក់ព័ន្ធស្នើសុំជួបប្រជុំពិភាក្សាទាក់ទិននឹងការងារ។

តាមរយៈនីតិវិធីជ្រើសរើសប្រកបដោយតម្លាភាព និងយុត្តិធម៌ ដោយផ្អែកលើទេពកោសល្យ កម្រិតវប្បធម៌ រួមជាមួយនឹងបទពិសោធន៍ការងារ លោក វណ្ណារ៉ា អាយុ៣៣ឆ្នាំ ត្រូវបានជ្រើសរើស និងតែងតាំងជានាយកប្រតិបត្តិថ្មីនៃ NGOF ចាប់ពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤តទៅ។

NGOF បាន និងកំពុងធ្វើការងារយ៉ាងសស្រាក់សស្រាំទៅលើកម្មវិធីផ្សេងៗដើម្បីធ្វើឲមានការប្រែប្រួលជាវិជ្ជមាននៅកម្ពុជា។ ប្រការនេះនាំមកនូវភារកិច្ច និងការទទួលខុសត្រូវជាច្រើនដែលតម្រូវឲ្យលោក វណ្ណារ៉ា ធ្វើការ និងដោះស្រាយជាមួយ។ ទន្ទឹមនឹងនេះ លោកក៏មានសុទិដ្ឋិនិយមខ្ពស់ជាមួយការខិតខំរបស់លោក ដោយលោកមានជំនឿយ៉ាងមុតមាំទៅលើឧត្តមភាពនៃការលើកទឹកចិត្ត និងការគាំទ្ររបស់សមាជិកភាព ដែលជាសមាសភាគដ៏សំខាន់សម្រាប់អភិវឌ្ឍន៍ការងារ។

នៅពេលយើងសួរលោកថាតើការងារអាទិភាពរបស់លោកមានអ្វីខ្លះជាមួយតួនាទីថ្មីនៅ NGOF លោកបានមានប្រសាសន៍ថា "ជាចំបងត្រូវសំដៅសម្រេចបាននូវផែនការយុទ្ធសាស្រ្តរយៈពេលវែង និងខ្លីរបស់យើងក្នុងពេលខាងមុខ ដោយផ្តោតការខិតខំ និងធនធានឆ្ពោះទៅលើអ្វីដែលជម្រុញឲ្យសម្រេចបានគោលដៅរបស់យើង។ ទន្ទឹមនឹងនេះ យើងចាំបាច់ត្រូវបន្តផ្តោតលើកម្មវិធីបច្ចុប្បន្នដើម្បីធានាឲ្យបាននូវ

ការធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាពស្របគ្នានឹងសមិទ្ធផល។ ដោយមានការខិតខំប្រឹងប្រែង គាំទ្រ និងការចូលរួមចំណែកយ៉ាងសកម្មពីអង្គការសមាជិកភាព អង្គការបណ្តាញ និងបុគ្គលិកទាំងអស់ ក្នុងការងារ ខ្ញុំជឿថាយើងអាចប្រែក្លាយកម្ពុជាឲ្យក្លាយជាទីកន្លែងកាន់តែប្រសើរឡើងមួយ។"

ក្នុងឋានៈជានាយកប្រតិបត្តិថ្មី ដែលដឹកនាំអង្គការទាំងមូល លោក វណ្ណារ៉ា មានគោលដៅជាក់លាក់គឺ ១)រក្សាកេរតំណែលដែលវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាមានឲបានល្អប្រសើរ ២)បន្តកិច្ចសហប្រតិបត្តការឲបានល្អប្រសើរជាមួយអង្គការសមាជិក អង្គការបណ្តាញ ម្ចាស់ជំនួយ ដៃគូ អភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីសំរេចបាននូវទស្សនៈវិស័យ និងបេសកកម្មរបស់វេទិកានេះ ៣)ពង្រឹងអង្គការសមាជិកបណ្តាញទាំង៨ឲបានរឹងមាំ និងខ្លាំងក្លា ក្នុងការបំរើសេវាកម្មប្រកបដោយប្រសិទ្ធិភាពទៅដល់ប្រជាជនដែលងាយរងគ្រោះ និងក្រីក្រ ៤)ធានា និងរក្សាឲអង្គការសង្គមស៊ីវិលនៅតែមានឱកាសគ្រប់គ្រាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សង្គម ហើយធ្វើជាកញ្ចក់ឆ្លុះបញ្ចាំងសំរាប់ការអភិវឌ្ឍន៍សង្គមឲកាន់តែប្រសើរ និងមានប្រសិទ្ធិភាពខ្ពស់ ៥)រៀបចំយុទ្ធសាស្រ្តត្រឹមត្រូវ ច្បាស់លាស់ក្នុងការបំរើសេវាកម្មឆ្លើតតបទៅនឹងសេចក្តីត្រូវការពិតប្រាកដរបស់អង្គការសមាជិកភាព និងអង្គការសមាជិកបណ្តាញ និងអ្នកពាក់ព័ន្ធ និង៦)ធ្វើឲវេទិកាអង្គការមិនមែន រដ្ឋាភិបាលស្តីពីកម្ពុជាក្លាយជាអង្គការគំរូល្អ និងមាននិរន្តរភាពនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ ដើម្បីសំរេចបាននូវកិច្ចការទាំងនេះ ទាមទារឲយើងមានទស្សនៈវិស័យច្បាស់លាស់ យុទ្ធសាស្រ្តត្រឹមត្រូវ ការខិតខំប្រឹងប្រែង ភាពអំណត់ ការលះបង់ ការតាំងចិត្តខ្ពស់ សាមគ្គីភាព ភាពជាគំរូល្អប្រកបដោយយុទ្ធសាស្រ្ត និងសុចរិតភាព។

ជាមួយគ្នានេះ លោក វណ្ណារ៉ា បានសង្កត់ធ្ងន់ថា បច្ចុប្បន្ននេះ កម្ពុជាមានធនធានមនុស្ស និងធនធានផ្សេងៗទៀតខ្លះហើយសំរាប់ធ្វើការអភិវឌ្ឍន៍ប្រទេស ប៉ុន្តែអ្វីដែលកម្ពុជានៅខ្វះខាតនោះ គឺការបណ្តុះភាពជាគំរូល្អសំរាប់ការគ្រប់គ្រង និងដឹកនាំ។ ដូច្នេះ ភាពជាគំរូល្អទាំងកាយវិការ និងស្មារតីពិតជាមានសារៈសំខាន់សំរាប់ចូលរួមក្នុងការអភិវឌ្ឍន៍អង្គការ ស្ថាប័ន ក៏ដូចជាប្រទេសជាតិ។

លោក វណ្ណារ៉ា ក៏បានឆ្លងកាត់ការសិក្សា និងការងារជាច្រើនឆ្នាំផងដែរ។ លោកបានទទួលនូវសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ចំនួន២ គឺបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចកសិកម្ម និងរអភិវឌ្ឍន៍ជនបទ ពីសាកលវិទ្យាល័យភូមិន្ទកសិកម្មនៅឆ្នាំ២០០៥ និងការសិក្សាស្តីពីការអភិវឌ្ឍន៍ ឯកទេសសាកលភាវូបនីយកម្ម និងការអភិវឌ្ឍន៍ពីវិទ្យាស្ថានក្រោយឧត្តមសិក្សាស្តីពីការអភិវឌ្ឍន៍(IUED)នៃទីក្រុងហ្សឺណែវប្រទេសស្វីសនៅឆ្នាំ២០០៧។

ផ្សារភ្ជាប់ជាមួយនឹងបទពិសោធន៍ការងាររយៈពេលជាង១១ឆ្នាំ ទៅលើការដឹកនាំ និងគ្រប់គ្រង ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ក៏ដូចជាការអភិវឌ្ឍសហគមន៍ជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និង រាជរដ្ឋាភិបាល លោកក៏បានធ្វើការសិក្សាស្រាវជ្រាវជាច្រើន និងបានបោះពុម្ពផ្សាយនូវរបាយការណ៍សិក្សារបស់លោកជាសាធារណៈចំនួន១៦ ទាក់ទិននឹងបរិស្ថាន ការគ្រប់គ្រងធនធានទឹក ការអភិវឌ្ឍអាងទន្លេ ការគ្រប់គ្រងព្រៃឈើ ជនជាតិដើមភាគតិច ដី ការប្រែប្រួលអាកាសធាតុ កសិកម្ម និងការតាំងទីលំនៅឋានថ្មី។ ក្រៅពីនេះ លោកធ្លាប់ត្រូវបានគេអញ្ជើញឲ្យធ្វើជាវាគ្មិនក្នុងសន្និសីទថ្នាក់តំបន់ និងអន្តរជាតិក្នុងប្រទេសចំនួន ៣៦ នៅជុំវិញពិភពលោក។ ជាមួយគ្នានេះដែរ តាំងពីឆ្នាំពី២០០៧ រហូតដល់ឆ្នាំ២០១២ លោក តឹក វណ្ណារ៉ា ជាសាស្ត្រាចារ្យ សំរាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដោយបង្រៀនលើមុខវិជ្ជាការគ្រប់គ្រងធនធានធម្មជាតិ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ។

ដោយក្រឡេកមើលទៅអតីតកាល លោក តឹក វណ្ណារ៉ា នៅឆ្នាំ១៩៩៩-២000 លោក ធ្វើជាគ្រូបង្រៀនកុំព្យូទ័រនៅអង្គការVYCD ហើយនៅឆ្នាំ២០០១-២០០៤ លោកធ្វើជាអ្នកស្រាវជ្រាវផ្នែកបរិស្ថាន និងអ្នកសម្របសម្រួលកម្មវិធីបោះពុម្ពនៃសមាគមថៃរក្សាបរិស្ថាន និងវប្បធម៌ ដែលកិច្ចការនេះ តំរូវឲលោកចុះធ្វើការស្រាវជ្រាវនៅគ្រប់ឃុំ ស្រុក ខេត្តនៃប្រទេសកម្ពុជា ហើយវាក៏បានជំរុញឲលោកក្លាយទៅជាអ្នកវិភាគ និងអ្នកសរសេរអត្ថបទលើប្រធានបទទាក់ទងនឹងបរិស្ថាន ធនធានធម្មជាតិ ជីវភាពរស់នៅ ជនជាតិដើមភាគតិច ការប្រែប្រួលអាកាសធាតុ ដែលជាសរុបលោកផលិតបាន៣១៥អត្ថបទ និងបានចុះផ្សាយនៅលើព្រឹត្តិបត្រជាតិ តំបន់ និងអន្តរជាតិចំនួន៥២លេខ។ ចាប់ពីឆ្នាំ២០០៥រហូតដល់ឆ្នាំ២០១២ លោកបានក្លាយជាបុគ្គលិកគ្រប់គ្រងកម្មវិធីនៃសមាគមថៃរក្សាបរិសាន និងវប្បធម៌ ដែលការងារនេះផ្តោតសំខាន់ទៅលើការអភិវឌ្ឍន៍សមាគម ការគ្រប់គ្រងបុគ្គលិកគំរោង ការដឹកនាំអនុវត្តគំរោង ការទំនាក់ទំនងជាមួយព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងសហគមន៍មូលដ្ឋាន ដើម្បីឲគ្រប់អ្នកពាក់ព័ន្ធទាំងអស់ បានជួបពិភាក្សាក្នុងការដោះស្រាយបញ្ហាជំលោះលើធនធានធម្មជាតិដោយសន្តិវិធី និងការកសាងច្បាប់គោលនយោបាយសំរាប់គ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងកំឡុងពេលនោះដែរ លោក វណ្ណារ៉ា បានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រង និងដឹកនាំអង្គការសមាជិកបណ្តាញនានា ដូចជានៅឆ្នាំ២០០៧-២០០៩ លោកត្រូវបានជាប់ឆ្នោត សំរាប់តួនាទីជាប្រធានគណៈកម្មការគ្រប់គ្រងនៃបណ្តាញសហគមន៍ទេសចរណ៍ធម្មជាតិកម្ពុជា ដែលមានអង្គការសាកលវិទ្យាល័យ និងស្ថាប័នរដ្ឋាភិបាលជាសមាជិកភាពចំនួន៣៥ ដែលក្នុងតួនាទីនេះ លោកបាន

ជំរុញឲមានការបង្កើតច្បាប់ និងគោលនយោបាយនានាពាក់ព័ន្ធនឹងទេសចរណ៍សហគមន៍។ បន្ថែមពីលើនេះ លោក តឹក វណ្ណារ៉ា បានជាប់ឆ្នោតក្នុងតួនាទីជាសមាជិកគណៈកម្មការគ្រប់គ្រងនៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាពីរអាណត្តិជាប់គ្នានៅក្នុងឆ្នាំ២០១០ និងឆ្នាំ២០១២ ហើយនៅក្នុងឆ្នាំ ២០០៧-២០១២ លោក ធ្វើជាប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលជាតិពន្ធុសាស្ត្រ និងបរិស្ថាន និងពីឆ្នាំ២០០៥-២០១០ លោកធ្វើជាអ្នកតំណាងប្រចាំប្រទេសនៃបណ្តាញទន្លេអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ និងជាពិសេសនៅឆ្នាំ២០១២ លោក តឹក វណ្ណារ៉ា បានទទួលពានរង្វាន់ល្អ(Excellence Award)លើការងារបរិស្ថានប្រចាំនៅអាស៊ីប៉ាស៊ីហ្វិច ពីមជ្ឈមណ្ឌលភាពជាអ្នកដឹកនាំ និងបរិស្ថាន និងកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិនៅសាកលវិទ្យាល័យជាតិកាំងវ៉ុន សាធារណៈរដ្ឋកូរេខាងត្បូង។

ជាមួយការអប់រំ និងបទពិសោធន៍ជាច្រើនឆ្នាំ យើងជឿជាក់ថាលោកពិតជាអាចបំពេញតួនាទីដឹកនាំការងាររបស់ NGOF ដោយផ្អែកលើចក្ខុវិស័យ បេសកកម្មនៃវេទិកា និងគ្រប់គ្រង NGOF ឲ្យដើរក្នុងទិសដៅត្រឹមត្រូវ ដើម្បីការកែលម្អកាន់តែប្រសើរឡើងនាពេលអនាគត និងអាចផ្តល់នូវសេវាដ៏ប្រសើរបំផុតជូនដល់អង្គការដៃគូ អង្គការសមាជិកភាព អង្គការសមាជិកបណ្តាញ រួមជាមួយនឹងប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះដែលត្រូវការជំនួយពីពួកយើងទាំងអស់។

**លោក តឹក វណ្ណារ៉ា នាយកប្រតិបត្តិនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អាចទំនាក់ទំនងបានតាមរយៈសារអេឡិចត្រូនិចៈ vannara@ngoforum.org.kh និងទូរស័ព្ទលេខៈ០១២ ៧៩៣ ៤៨៩។**